**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១១៥៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងក្រុមប្រឹក្សាភិបាល នៃ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី ៤

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៤ ស្តីពីការផ្ទេររដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ឱ្យស្ថិតនៅក្រោមអាណាព្យាបាលនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

**ស ម្រេ ច**

**មាត្រា ១ :** តែងតាំងក្រុមប្រឹក្សាភិបាលនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី ៤ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១-ឯកឧត្តម **ម៉េង សក្តិធារ៉ា** | អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្ម តំណាងក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល | ប្រធាន |
| ២-ឯកឧត្តម ឯក សុនចាន់ | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | សមាជិក |
| ៣-ឯកឧត្តម អ៊ីវ ខេង | អនុរដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

Downloaded from http://www.khmerlaws.com

| | | | |
|---|---|---|---|
| ៤-ឯកឧត្តម | ជូ វិជិត្ត | អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥-ឯកឧត្តម | ម៉ាន់ ឈឿន | អភិបាលរងរាជធានីភ្នំពេញ តំណាងសាលារាជធានីភ្នំពេញ | សមាជិក |
| ៦-លោក | ហុង ស៊ីលីន | អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅនៃក្រសួងមហាផ្ទៃ តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៧-លោក | ឡុង ណារ៉ូ | អគ្គនាយករង ទទួលបន្ទុកជំនួយការអគ្គនាយកលើការងារបច្ចេកទេស តំណាងនិយោជិតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | សមាជិក |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង ៗ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ [illegible] កក្កដា ឆ្នាំ ២០០៩ .

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Downloaded from http://www.khmerlaws.com